ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តស្វាយរៀង

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៦
ចុះថ្ងៃទី ២១-០១-២០២០

សាលក្រមព្រហ្មទណ្ឌលេខ ២៧៩ "ឆ"
ចុះថ្ងៃទី ០៥-០៨-២០២០

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តស្វាយរៀង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តស្វាយរៀង នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ និងប្រកាសសាលក្រម នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តស្វាយរៀង

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្វាយរៀង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តស្វាយរៀង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដែលមាន ៖

ជនជាប់ចោទឈ្មោះ [redacted] **គុំ ហៅ ម៉ូស** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តស្វាយរៀង មានទីលំនៅបច្ចុប្ប[redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ដោ (ស) ម្តាយឈ្មោះ [redacted] សុម៉ាលី (រ) នៅលើប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៧៩បឃ.ឌ/២០ ចុះថ្ងៃទី២១-០១-២០២០)

ជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិពោធិ៍ថ្មី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ពិសិដ្ឋ** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងសំណង់ មានទីលំនៅបច្ចុប្បន្ននៅ ភូមិពោធិ៍ថ្មី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ** ៖ លោកមេធាវី [redacted] និងលោកមេធាវី [redacted] មានអាសយដ្ឋាននៅការិយាល័យអគារលេខ១១៥៩ ផ្លូវជាតិលេខ២ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted]គុំ ។

### ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៤៥នាទី នៅចំណុចភូមិពោធិ៍ថ្មី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសមួយកើតឡើងបង្កដោយជនជាប់ចោទឈ្មោះ [redacted]គុំ បានធ្វើសកម្មភាពយកដែកគាស់ដែកវាយលើឈ្មោះ [redacted] ពិសិដ្ឋ ត្រូវចំភ្លៅខាងឆ្វេង ដែលជាកន្លែង

ធ្លាប់បាក់ពីមុនមិនទាន់ដោះដែកចេញនោះ បណ្តាលឲ្យរងរបួសបាក់ឆ្អឹងភ្លៅបន្ថែមទៀត។ មូលហេតុផឹកស្រាស្រវឹងទាស់ពាក្យសម្តីគ្នា ហើយឈ្មោះ [redacted] ពិសិដ្ឋ បានហូតខ្សែក្រវ៉ាត់វាយលើឈ្មោះ [redacted] កុំ ហើយជនសង្ស័យក៏បានទៅផ្ទះយកដែកគាស់វាយលើឈ្មោះ [redacted] ពិសិដ្ឋ វិញតែម្តង។ ក្រោយពេលកើតហេតុ ជនរងគ្រោះត្រូវបានក្រុមគ្រួសារបញ្ជូនទៅកាន់មន្ទីរពេទ្យ។ រីឯជនសង្ស័យត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន កសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] កុំ បានឆ្លើយនាពេលវនាការថា ចំពោះការចោទប្រកាន់ខ្លួនទទួលស្គាល់។ ថ្ងៃកើតហេតុ ខ្លួនបានទៅលេងបុណ្យវត្តជាមួយឈ្មោះ ពិសិដ្ឋ ជាជនរងគ្រោះ ហើយម៉ោង១២យប់ ក៏បានបបួលគ្នាមកផឹកផ្ទះឈ្មោះ លក្ខិណា ហើយពេលផឹកក៏មានទាស់សម្តីគ្នាជាមួយឈ្មោះ សាលី ហើយពេលនោះឈ្មោះ ពិសិដ្ឋ បានទៅឃាត់ ហើយពុំឈប់ចំណែកឈ្មោះ ពិសិដ្ឋ ក៏បានយកខ្សែក្រវ៉ាត់មកវាយខ្លួនមុន ពេលនោះខ្លួនខឹង ក៏បានរត់ទៅយកដែកដកដែកគោលមករកវាយឈ្មោះ ពិសិដ្ឋ តែពុំទាន់បានវាយទេ ឈ្មោះ ពិសិដ្ឋ ក៏បានលោតចុះពីលើគ្រែ ហើយបាក់ជើង ដែលរបួសស្រាប់ពីករណីគ្រោះថ្នាក់ចរាចរណ៍ ហើយកំពុងតដែកតែម្តង។ ពេលឈ្លោះ គឺជាមួយឈ្មោះ សាលី ឈ្មោះ ប៊ុនធឿន និងឈ្មោះ សំដាបើន។ ខ្លួនបានបម្រុងយកដែកដកដែកគោលបម្រុងវាយ តែឈ្មោះ ពិសិដ្ឋ បានលោតចុះពីលើគ្រែបាក់ជើង តែម្តង។ ឈ្មោះ ពិសិដ្ឋ ជាមិត្តភក្តិ ហើយដោយសារឈ្មោះ ពិសិដ្ឋ មកឃាត់ និងដកខ្សែក្រវ៉ាត់វាយខ្លួនមុន ទើបបានទៅយកដែកដកដែកគោលមកបម្រុងវាយ តែពុំទាន់បានវាយ ក៏ឈ្មោះ ពិសិដ្ឋ លោតចុះពីលើគ្រែបាក់ជើងរបួសថែម។ ខ្លួនដឹងកំហុស។ ខ្លួនទទួលស្គាល់ថា បានវាយជនរងគ្រោះ បានដេញវាយ តែវាយត្រូវដែកក្រោមភ្លៅ។ ខ្លួនពិតជាបានយកដែកទៅវាយជនរងគ្រោះត្រូវភ្លៅ តែពុំធ្ងន់ធ្ងរទេ។ ខ្លួនមានការសោកស្តាយ ព្រមទទួលស្គាល់កំហុស ហើយ។ ខ្លួនរៀនថ្នាក់ទី១១។ ចំពោះសំណងទៅជនរងគ្រោះ ខ្លួនចាំពិភាក្សាជាមួយគ្រួសារខ្លួនសិន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនាពេលសវនាការថា ដំបូងខ្លួនចេញពីវត្ត ហើយបងឈ្មោះ សៃ បានតេរហៅឲ្យមកផឹកផ្ទះលក្ខិណា បន្ទាប់មកឈ្មោះ [redacted] កុំ ក៏បានជិះម៉ូតូមក ហើយបានចូលផឹក រួចក៏មានការឈ្លោះទាស់ទែងគ្នាជាមួយឈ្មោះ សាលី បន្ទាប់មក ខ្លួនក៏បានទៅឃាត់ថា សុទ្ធតែមិត្តភក្តិគ្នាទេ ឈ្លោះគ្នាធ្វើអី បន្ទាប់មក ក៏បានយកខ្សែក្រវ៉ាត់ក្រវាសត្រូវដៃឈ្មោះ [redacted] កុំ ហើយក្រោយមក ឈ្មោះ កុំ ក៏បានខឹង រត់ទៅយកដែកដកដែកគោលមកដេញវាយ ហើយខ្លួន និងអ្នកផ្សេងក៏បានរត់ទាំងអស់គ្នា ឈ្មោះ [redacted] កុំ ក៏ដេញវាយ ហើយក៏វាយត្រូវដែកតជើងខ្លួនជាប់ដែកនៅភ្លៅ ហើយឈ្មោះ [redacted] កុំ ក៏រត់ទៅផ្ទះ ហើយមិត្តភក្តិក៏បានជួយ ហើយយកទៅព្យាបាល។ គាត់វាយត្រូវជើងខាងឆ្វេង ខាងក្រោមត្រគាក។ វាយត្រូវបាក់ឆ្អឹង ឃើញឆ្អឹងចេះមកក្រៅ ។ ចំពោះរបួសគ្រោះថ្នាក់ចរាចរណ៍ គឺនៅកន្លែងផ្សេងនោះទេ ពុំមែនកន្លែងវាយនោះទេ។ សំណងខ្លួនទាមទារ។ ថ្លៃព្យាបាលចំណាយអស់៥២០០ដុល្លារ មានវិក័យបត្រពុំទាន់បានដាក់ជូនតុលាការទេ ។ ខ្លួនទាមទារសំណងថ្លៃព្យាបាលចំនួន៥០០០ដុល្លារ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន ដូចនេះតំណាងអយ្យការសុំតម្កល់បទចោទ និងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល។ ដូច្នេះ ប្តឹងសុំចៅក្រមជំនុំជម្រះពិចារណាសម្រេចផ្តន្ទាទោសទៅតាមច្បាប់។

-លោកមេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] កុំ បានឆ្លើយសារភាពជូនតុលាការ ដែលមានការភ្ញាក់រលឹកដឹងកំហុស ស្តាយក្រោយនូវអំពើដែលខ្លួនបានប្រព្រឹត្ត មានការដឹងកំហុស ដូចនេះ តាមមូលហេតុនេះ ជនជាប់ចោទ

គួរទទួលបាននូវការផ្តល់ស្ថានសម្រាលទោស និងការបន្ធូរបន្ថយទោសឲ្យជនជាប់ចោទ ហើយចំពោះសំណងរដ្ឋប្បវេណី ដែលដើមបណ្តឹងរដ្ឋប្បវេណី បានទាមទារឃើញថា កូនក្តីខ្លួនពុំមានលលទ្ធភាពសងនោះឡើយ ហើយដើមបណ្តឹងរដ្ឋប្បវេណី ក៏ពុំមានភស្តុតាងបញ្ជាក់អំពីការទាមទារដាក់ជូនតុលាការផងដែរ ម្យ៉ាងវិញទៀត តាមការពិភាក្សាដេញដោលឃើញថា អំពើរបស់ជនជាប់ចោទ ក៏ពុំមានលក្ខណៈធ្ងន់ធ្ងរដែលនាំឲ្យមានព្យសនកម្មធ្ងន់ធ្ងរទៅដល់ជនរងគ្រោះផងដែរ ដែលពុំដូចអ្វីដែលជនរងគ្រោះបានលើកឡើងថា ថ្លៃព្យាបាលអស់៥២០០ដុល្លារនោះដែរ ដូចនេះ តាមការសន្និដ្ឋានខាងលើ សូមលោកចៅក្រមពិចារណាផ្តល់ស្ថានសម្រាលទោសដោយធ្វើការបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួន ព្រមទាំងអនុវត្តទោសព្យួរឲ្យជនជាប់ចោទ និងសម្រេចឲ្យសងសំណងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីតាមសភាពជាក់ស្តែង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] កុំ បានឆ្លើយថា ខ្លួនសូមសំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង ដោយខ្លួនដឹងកំហុស ហើយសន្យាថាឈប់ប្រព្រឹត្តខុសទៀតហើយ។

**ក្រោយពីបានពិនិត្យសំណុំរឿង និង ពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់រួចហើយ**

## សាលាដំបូងខេត្តស្វាយរៀង

## យល់ឃើញថា

១-ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] កុំ មកជំនុំជម្រះពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិពោធិ៍ថ្មី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។ តុលាការអាចយករឿងនេះ មកជំនុំជម្រះតាមមាត្រា ២០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន ដូចនេះតំណាងអយ្យការសុំតម្កល់បទចោទ និងដីកាសន្និដ្ឋានស្ពាពរទុកជាបានការដដែល។ ដូច្នេះ ប្តឹងសុំចៅក្រមជំនុំជម្រះពិចារណាសម្រេចផ្តន្ទាទោសទៅតាមច្បាប់។។ ចំពោះសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ គឺមានភាពសមស្រប ដែលតុលាការអាចយកមកពិនិត្យ និងសម្រេចតាមផ្លូវច្បាប់បាន ។

៣-ជនជាប់ចោទឈ្មោះ [redacted] កុំ បានឆ្លើយនាពេលសវនាការ ដោយបានទទួលស្គាល់ថា ចំពោះការចោទប្រកាន់ខ្លួនទទួលស្គាល់។ ថ្ងៃកើតហេតុ ខ្លួនបានទៅលេងបុណ្យវត្តជាមួយឈ្មោះ ពិសិដ្ឋ ជាជនរងគ្រោះ ហើយម៉ោង១២យប់ក៏បានបបួលគ្នាមកផឹកផ្ទះឈ្មោះ លក្ខិណា ហើយពេលផឹកក៏មានទាស់សម្តីគ្នាជាមួយឈ្មោះ សាលី ហើយពេលនោះឈ្មោះ ពិសិដ្ឋ បានទៅឃាត់ ហើយពុំឈប់ចំណែកឈ្មោះ ពិសិដ្ឋ ក៏បានយកខ្សែក្រវ៉ាត់មកវាយខ្លួនមុន ពេលនោះខ្លួនខឹង ក៏បានរត់ទៅយកដែកដកដែកគោលមករកវាយឈ្មោះ ពិសិដ្ឋ តែពុំទាន់បានវាយទេ ឈ្មោះ ពិសិដ្ឋ ក៏បានលោតចុះពីលើគ្រែ ហើយបាក់ជើង ដែលរបួសស្រាប់ពីករណីគ្រោះថ្នាក់ចរាចរណ៍ ហើយកំពុងតដែកតែម្តង។ ពេលឈ្មោះ គឺជាមួយឈ្មោះ សាលី ឈ្មោះ ប៊ុនធឿន និងឈ្មោះ សំដាលីន។ ខ្លួនបានបម្រុងយកដែកដកដែកគោលបម្រុងវាយ តែឈ្មោះ ពិសិដ្ឋ បានលោតចុះពីលើគ្រែបាក់ជើង តែម្តង។ ឈ្មោះ ពិសិដ្ឋ ជាមិត្តភក្តិ ហើយដោយសារឈ្មោះ ពិសិដ្ឋ មកឃាត់ និងដកខ្សែក្រវ៉ាត់វាយខ្លួនមុន ទើបបានទៅយកដែកដកដែកគោលមកបម្រុងវាយ តែពុំទាន់បានវាយ ក៏ឈ្មោះ ពិ

សិដ្ឋ លោតចុះពីលើគ្រែបាក់ជើងរបួសថែម។ ខ្លួនដឹងកំហុស។ ខ្លួនទទួលស្គាល់ថា បានវាយជនរងគ្រោះ បានដេញវាយ តែវាយត្រូវដែកក្រោមភ្លៅ។ ខ្លួនពិតជាបានយកដែកទៅវាយជនរងគ្រោះត្រូវភ្លៅ តែពុំធ្ងន់ធ្ងរទេ។ ខ្លួនមានការសោកស្តាយ ព្រមទទួលស្គាល់កំហុសហើយ។ ខ្លួនរៀនថ្នាក់ទី១១។ ចំពោះសំណងទៅជនរងគ្រោះ ខ្លួនចាំពិភាក្សាជាមួយគ្រួសារខ្លួនសិន។

៤-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ គឺមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ពិសិដ្ឋ ដែលបានឆ្លើយនាពេលសវនាការថា ដំបូងខ្លួនចេញពីវត្ត ហើយបងឈ្មោះ សែ បានគេហៅឲ្យមកផឹកផ្ទះលក្ខិណា បន្ទាប់មកឈ្មោះ [redacted] កុំ ក៏បានជិះម៉ូតូមក ហើយបានចូលផឹក រួចក៏មានការឈ្លោះទាស់ទែងគ្នាជាមួយឈ្មោះ សាលី បន្ទាប់មក ខ្លួនក៏បានទៅឃាត់ថា សុទ្ធតែមិត្តភក្តិគ្នាទេ ឈ្លោះគ្នាធ្វើអី បន្ទាប់មក ក៏បានយកខ្សែក្រវ៉ាត់ក្រវាត់ត្រូវដៃឈ្មោះ [redacted] កុំ ហើយក្រោយមក ឈ្មោះ កុំ ក៏បានខឹង រត់ទៅយកដែកដកដែកគោលមកដេញវាយ ហើយខ្លួន និងអ្នកផ្សេងក៏បានរត់ទាំងអស់គ្នា ឈ្មោះ ភិន កុំ ក៏ដេញវាយ ហើយក៏វាយត្រូវដែកគជើងខ្លួនជាប់ដែកនៅភ្លៅ ហើយឈ្មោះ [redacted] កុំ ក៏រត់ទៅផ្ទះ ហើយមិត្តភក្តិក៏បានជួយ ហើយយកទៅព្យាបាល។ គាត់វាយត្រូវជើងខាងឆ្វេង ខាងក្រោមត្រគាក។ វាយត្រូវបាក់ឆ្អឹង ឃើញឆ្អឹងចេះមកក្រៅ ។ ចំពោះរបួសគ្រោះថ្នាក់ចរាចរណ៍ គឺនៅកន្លែងផ្សេងនោះទេ ពុំមែនកន្លែងវាយនោះទេ។ សំណងខ្លួនទាមទារ។ ថ្លៃព្យាបាលចំណាយអស់៥២០០ដុល្លារ មានវិក័យបត្រពុំទាន់បានដាក់ជូនតុលាការទេ ។ ខ្លួនទាមទារសំណងថ្លៃព្យាបាលចំនួន៥០០០ដុល្លារ។

៥-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ និងចម្លើយរបស់សាក្សី ឃើញថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនាទៅលើជនរងគ្រោះប្រាកដមែន ដែលអំពើរបស់ជនជាប់ចោទនេះ គឺជាបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដែលប្រព្រឹត្តដោយប្រើអាវុធ។ ហេតុដូច្នេះ ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ និងចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងក្នុងសំណុំរឿង គឺមានធាតុផ្សំគ្រប់គ្រាន់ ដែលកំណត់បានថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៦-ដោយផ្អែកលើសំអាងហេតុខាងលើ គឺតុលាការអាចកំណត់បានថា មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] កុំ ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចភូមិពោធិ៍ថ្មី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទឈ្មោះ [redacted] កុំ បានឆ្លើយសារភាពជូនតុលាការ ដោយបានទទួលស្គាល់នូវកំហុសរបស់ខ្លួន និងបានស្នើសុំតុលាការបន្ធូរបន្ថយទោស។ ផ្អែកតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា "អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើហិង្សានេះ ប្រព្រឹត្តៈ១-ដោយមានការគិតទុកជាមុន ២-ដោយប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ៣-ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត" ។ តុលាការយល់ឃើញថា ជនជាប់ចោទ បានឆ្លើយសារភាពជូនតុលាការ និងបានស្នើសុំតុលាការបន្ធូរបន្ថយទោស។ ម្យ៉ាងវិញទៀត ព្យសនកម្មក្នុងរឿងនេះ ពុំមានលក្ខណៈធ្ងន់ធ្ងរ ហើយជនជាប់ចោទ ក៏បានសងសំណងខូចខាតទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីរួចហើយដែរនោះ គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទក្នុងកម្រិតទោស ស្របទៅតាមអំពើ និងទំហំព្យសនកម្ម ដែលជនជាប់ចោទបានប្រព្រឹត្ត ដូចមានចែងក្នុងមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ ព្រមទាំងព្យួរទោសឲ្យជនជាប់ចោទដែលបានឆ្លើយសារភាពជូនតុលាការ ដោយយោងតាមមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា

Scanned with CamScanner

១០៨ នៃក្រមព្រហ្មទណ្ឌ ។

៨-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ពិសិដ្ឋ បានដាក់ពាក្យស្នើសុំដកពាក្យបណ្តឹងមកតុលាការ ដោយបានលើកមូលហេតុថា នៅក្នុងរឿងនេះ ខ្លួនបានទទួលសំណងសមរម្យពីគ្រួសារជនជាប់ចោទរួចហើយ ដូចនេះ ខ្លួនស្នើសុំដកពាក្យបណ្តឹងឈប់ប្តឹងទៅលើជនជាប់ចោទចាប់ពីពេលនេះតទៅ។ ហេតុដូច្នេះ ដោយសារដើមបណ្តឹងរដ្ឋប្បវេណី បានទទួលសំណងរួចហើយនោះ តុលាការនឹងមិនពិចារណាសម្រេចអំពីសំណងរដ្ឋប្បវេណីទៅឲ្យជនរងគ្រោះនោះឡើយ។

៩-វត្ថុចាប់យកមាន ដែកគាស់ មានមុខពីរ មានប្រវែង៦០,៣សង្ទីម៉ែត្រ មានមុខកាត់ប្រវែង២.៥សង្ទីម៉ែត្រ ពណ៌ក្រម៉ៅ ចំនួនមួយ ដែលដកហូតបាន គឺជាវត្ថុដែលជនជាប់ចោទប្រើប្រាស់សម្រាប់ការប្រព្រឹត្តបទល្មើសនោះ គប្បីតុលាការធ្វើការរឹបអូសបំផ្លាញចោលវត្ថុចាប់យកនេះ ដោយយោងតាមមាត្រា ២២៩ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោស** ជនជាប់ចោទឈ្មោះ [redacted] **កុំ ហៅ ម៉ូស** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់២(**ពីរ**)**ឆ្នាំ** តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល០៧ **(ប្រាំពីរ)**ខែ ទោសសល់ពីនេះ **ត្រូវព្យួរធម្មតា** ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចភូមិពោធិ៍ថ្មី ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

**២-រឹបអូសបំផ្លាញចោលវត្ថុចាប់យក** ដែកគាស់ មានមុខពីរ មានប្រវែង៦០,៣(ហុកសិបក្បៀសបី) សង្ទីម៉ែត្រ មានមុខកាត់ប្រវែង២,៥(ពីរក្បៀសប្រាំ)សង្ទីម៉ែត្រ ពណ៌ក្រម៉ៅ ចំនួនមួយ ដែលដកហូតបានពីជនជាប់ចោទ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **កុំ ហៅ ម៉ូស** នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ។

សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

-បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម-
*ថ្ងៃពុធ ១រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*ស្វាយរៀង* ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រម**

[redacted]



Scanned with CamScanner